# ប្រាសាទបុសរាម

ជាទូទៅ បើគេរាប់អំពីប្រាសាទបុរាណមានអាយុកាលស្ថិតនៅក្នុងរចនាបថព្រៃក្មេងដែលស្ថិតនៅស្ថានភាពល្អប្រសើរ គឺមិនសូវមានច្រើនប៉ុន្មានឡើយ។ ភាគច្រើនប្រាសាទទាំងនោះបាក់បែកនៅសល់តែគ្រឹះប៉ុណ្ណោះ ឧទាហរណ៍ ប្រាសាទព្រៃក្មេង ជាដើម។ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញអំពីប្រាសាទមួយដែលអាចចាត់បញ្ចូលជាសិល្បៈរចនាបថព្រៃក្មេង (គ.ស.៦៣៥ ដល់ ៧០០) ដែលមានឈ្មោះថា "ប្រាសាទបុសរាម"។ ប្រាសាទនេះ មានទីតាំងស្ថិតនៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុក ភូមិសំបូរ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលស្ថិតនៅខាងជើងក្រុមប្រាសាទសំបូរ ចម្ងាយប្រមាណ ៧០០ ម៉ែត្រ។ តើប្រាសាទបុសរាម មានប្រវត្តិ និងលក្ខណៈដូចម្ដេចខ្លះ?

យោងតាមរយៈអត្ថបទស្រាវជ្រាវដែលមានចំណងជើងថា "L'art Khmer Primitif" (សិល្បៈខ្មែរសម័យដំបូង) របស់លោក Henri Parmentier លោកបានចុះបញ្ជីប្រាសាទនេះដោយតាងដោយ "ប្រាង្គ N24" ពោល គឺលោកមិនបានកត់ត្រាឈ្មោះ "បុសរាម" ដែលអ្នកស្រុកកំពុងហៅបច្ចុប្បន្ននេះឡើយ។ យើងមិនដឹងច្បាស់លាស់ថាការដែលអ្នកស្រុកហៅឈ្មោះប្រាសាទថាបែបនេះ មានចាប់តាំងពីពេលណាមកនោះឡើយ។ ម្យ៉ាងវិញទៀត ប្រសិនបើយើងយកឈ្មោះនេះមកបកស្រាយអំពីប្រភព និងអត្ថន័យដើម ក៏មិនមែនជាការងាយស្រួលនោះដែរ។ ពាក្យ "បុស" អាចជាភាសាខ្មែរ ឬជាពាក្យក្លាយមកពីភាសាសំស្ក្រឹត។ ប្រសិនជាខ្មែរ "បុស" សំដៅដល់ចំការចាស់ដែលគេទុកចោលមួយឆ្នាំ ឬពីរឆ្នាំ ហើយទីនោះនឹងមានលាស់ល្បាស់ឈើថ្មីឡើងវិញ ហើយបើទីនោះស្រឡះអស់គេលែងហៅ "បុស" ហើយ គេនឹងហៅ "ចំការ" ជំនួសវិញ។ ប្រសិនបើពាក្យនេះជាភាសាសំស្ក្រឹត គឺត្រូវនឹងពាក្យថា "បុស្ប" (ខ្មែរអានថា "បុស" ដោយសារខ្មែរមិនអានស្រះខ្វី) ដែលមានន័យថា "ផ្កា"។ រីឯពាក្យ "រាម" ក៏អាចជាពាក្យក្នុងភាសាខ្មែរ និងសំស្ក្រឹតដូចគ្នាដែរ ពោលបើជាខ្មែរមានន័យថា កូនឈើតូចៗ ឬឈើដែលងាប់ ដែលជាទូទៅខ្មែរតែងនិយាយភ្ជាប់ថា "រាមឈើ" (ឧទាហរណ៍៖ "ប្រមូលរាមឈើយកទៅដុត" ឬ "កាប់រាមឈើធ្វើទ្រើងត្រឡាច"។ លើសពីនេះ រាម ក៏ជាអាចនាមសព្ទសំដៅដល់ "រនាម" ដែលមានន័យថា ព្រៃស្ទាប់ក្នុងទំនាបបឹង ដងស្ទឹង ដងអូរជាដើម (ឧទាហរណ៍៖ ព្រៃរនាម ឬ ឈើរនាម)។ បើជាភាសាសំស្ក្រឹតវិញ ពាក្យ "រាម" ជានាមសព្ទមានន័យថា "ស្ទឹកឈើអែម" និងជាគុណនាមមានន័យថា "ពណ៌ខ្មៅ"។ ម៉្យោះហើយ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ឈ្មោះថា “**បុសរាម**” យើងពិបាកកំណត់ន័យដើមណាស់ ពោល គឺបើជាភាសាខ្មែរអាចសំដៅដល់ “**បុស ឬចំការដែលមានឈើតូចៗ**” ឬ **បុសដែលមានព្រៃដុះមាត់អូរ** (ប្រាសាទនេះនៅមិនឆ្ងាយពីអូរគ្រូកែ)។ ម្យ៉ាងវិញទៀត ប្រសិនបើឈ្មោះនេះក្លាយមកពីភាសាសំស្ក្រឹត វាអាចមានន័យថា “**ផ្កាឈើអែម**” ឬ “**ផ្កាខ្មៅ**”។

លោក Henri Parmentier បានលើកឡើងថា ប្រាសាទបុសរាម ជាសំណង់ទោលកសាងឡើងអំពីឥដ្ឋដែលនៅរូបរាងល្អ និងមានលក្ខណៈស្ថាបត្យកម្មប្លែកពីសំណង់ផ្សេងទៀតនៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុក។ លោកយល់ដូច្នេះមកពីសំណង់នេះមានទ្វារបញ្ឆោតប្លែកពីប្រាសាទផ្សេងៗទៀតក្នុងក្រុមខាងជើងជាមួយគ្នា។ ប្រាសាទបុសរាម មានរាងបួនជ្រុងទ្រវែង បែរមុខនិងមានទ្វារចូលនៅទិសខាងកើត ព្រមទាំងជញ្ជាំងបីទិសផ្សេងទៀតលម្អជាទ្វារបញ្ឆោត។ តាមរយៈការថតរូបពីលើអាកាស (LIDA) និងស្លាកស្នាមបច្ចុប្បន្ន សំណង់នេះហ៊ុមព័ទ្ធដោយកំពែងថ្មបាយក្រៀម ប៉ុន្តែ កំពែងថ្មបាយក្រៀមនេះបានដួលរាបដល់ដី ហើយកន្លែងខ្លះពំនូកដីចាក់បង្គរមើលលែងយល់ទៅហើយ។ កាន់តែគួរឱ្យចាប់អារម្មណ៍ នៅជ្រុងឦសានខាងក្រៅកំពែងថ្មបាយក្រៀម មានស្រះទឹកតូចមួយដែលមានរៀបថ្មបាយក្រៀមជុំវិញ។ លក្ខណៈបែបនេះ គឺមានភាពដូចគ្នាជាមួយក្រុមប្រាសាទតោ (ក្រុមកណ្ដាល)។

នៅផ្នែកខាងក្នុងប្រាសាទ សិល្បកររៀបជាបន្ទប់សក្ការបូជា (គភ៌គូហ) មានរាងបួនជ្រុងទ្រវែងដូចប្រាសាទផ្សេងៗទៀតដែរ។ ប៉ុន្តែ នៅតាមក្បាលជញ្ជាំងមិនមានរៀបថ្មភក់ធ្វើជាពិតាន និងមិនមានស្លាកស្នាមទបង្ហូរទឹកមន្តទៅទិសខាងជើង (សោមសូត្រ) ដូចប្រាសាទផ្សេងៗនៅក្រុមខាងជើងឡើយ។ តាមរយៈកំណាយរបស់អាជ្ញាធរជាតិសំបូរព្រៃគុកនៅពេលថ្មីៗនេះ នៅខាងក្នុងគភ៌គូហប្រាសាទ គេមិនបានរកឃើញស្លាកស្នាមឬបំណែកជើងទណាមួយឡើយ។ បន្ថែមពីនេះ បូកផ្សំជាមួយប្រាសាទនេះពុំមានបន្សល់ទុកសិលាចារឹក និងមិនមានភស្តុតាងផ្នែកបុរាណវិទ្យាណាមួយបញ្ជាក់ យើងមិនដឹងច្បាស់ថា កាលដើមឡើយនៅខាងក្នុងប្រាសាទបុសរាមគេតម្កល់អាទិទេពណាមួយនោះឡើយ។

ក្រឡេកមកមើលផ្នែកខាងក្រៅប្រាសាទវិញ ផ្នែកដំបូលមួយភាគធំបានបាក់បែកស្ទើរអស់ទៅហើយ។ ប៉ុន្តែ ផ្នែកដែលនៅសល់តិចតួចនៅទ្វារបញ្ឆោតខាងជើង ខាងត្បូង និងខាងលិច ជា

ពិសេសថ្នាក់ក្រោមបង្អស់នៃដំបូលប្រាសាទបុសរាម គឺបង្ហាញឱ្យឃើញថា ផ្នែកដំបូលប្រាសាទនេះមានលក្ខណៈស្រដៀងគ្នាច្រើនជាមួយផ្នែកដំបូលនៃប្រាសាទជ្រៃ (ប្រាង្គ N18) ពោល គឺជាប្រភេទដំបូលដែលមានក្បាច់លម្អជាវិមានតូចៗ *(Vimāna)* ចំនួន ៣ តម្រៀបគ្នា *(វិមានកណ្ដាលធំជាងគេភ្ជាប់ពីក្បាច់ទ្វារបញ្ឆោត)* ជាថ្នាក់ៗចំនួន ៣ ជាន់ ដែលគេស្គាល់ជាទូទៅថាជាប៉មដំបូលមានឥទ្ធិពលពីសិល្បៈឥណ្ឌាខាងត្បូងឈ្មោះថា "**រចនាបថដ្រាវិដ**" *(Dravida style)*។ ជាទូទៅ ក្បាច់ដំបូលដែលមានថ្នាក់រូបវិមានបែបនេះ គឺបង្ហាញឱ្យឃើញអំពីចម្លាក់គុឌុ (Kuḍu) នៅតាមវិមានដែលមានចម្លាក់មុខមនុស្សឬទេពនៅខាងក្នុង ។ ជាក់ស្ដែង ចម្លាក់គុឌុដែលអាចមើលឃើញនៅប្រាសាទបុសរាម យើងឃើញនៅសល់តាមក្បាលជញ្ជាំងប៉ុណ្ណោះ។ ក្បាលជញ្ជាំងប្រាសាទទៀតសោត មានលម្អបន្ថែមដោយក្បាច់តម្រៀបគ្នាជាជួរចំនួន ៣ ថ្នាក់ ពោល គឺថ្នាក់ខាងក្រោមលម្អជាក្បាច់បង្កាន់ដៃ (balustres) ឬហៅតាមឥណ្ឌាថា "កុម្ភស្តម្ភ" (Kumbha-Stambha) ថ្នាក់កណ្ដាលជាក្បាច់ត្របកឈូក និងខាងលើបង្អស់ជាចម្លាក់សត្វហង្សកំពុងត្រដាងស្លាប។

រីឯផ្នែកខឿនរបស់ប្រាសាទ (ខាងក្រោម) យើងពុំដឹងថាមានក្បាច់លម្អបែបណានោះទេ ព្រោះសព្វថ្ងៃខឿនប្រាសាទនេះកប់ដោយគំនរឥដ្ឋ និងពំនូកដីអស់ទៅហើយ។ អ្វីដែលគួរចាប់អារម្មណ៍ជាងគេនៃប្រាសាទបុសរាម គឺការលម្អនៅតាមទ្វារបញ្ឆោត។ ចំពោះទ្វារបញ្ឆោតខាងជើងសព្វថ្ងៃ គឺហ៊ុមព័ទ្ធដោយឫសដើមជ្រៃបាំងជិតទៅហើយ ម៉្លោះហើយយើងមិនអាចមើលក្បាច់លម្អបានទេ។ ប៉ុន្តែ ក្បាច់លម្អនៅទ្វារបញ្ឆោតដែលនៅល្អច្រើនជាងគេ គឺទ្វារបញ្ឆោតខាងលិច។ ទ្វារបញ្ឆោតបែបនេះ មិនដូចទ្វារបញ្ឆោតប្រាសាទផ្សេងទៀតនៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុកឡើយ ពោល គឺគ្រាន់តែស្រដៀងច្រើនជាមួយទ្វារបញ្ឆោតប្រាសាទជ្រៃ តែមិនដូចទាំងស្រុង។ ពោល គឺផ្ទៃជញ្ជាំងទាំងមូលខណ្ឌចែកដោយក្បាច់សសរផ្ដោបចំនួន ៤ ដើម ហើយនៅចន្លោះសសរផ្ដោបកណ្ដាល សិល្បករបន្ថែមសសរផ្ដោបពីរទៀតទ្រក្បាច់ខាងលើជារបៀបទ្វារបញ្ឆោត។ តាមការរៀបរាប់របស់លោក Henri Parmentier ចម្លាក់នៅទ្វារបញ្ឆោតខាងលិច មានលម្អរូបមនុស្សនិងសត្វនៅក្បែរគ្នា ប៉ុន្តែសព្វថ្ងៃរលុបអស់ពាក់កណ្ដាលហើយ (រលុបផ្នែកខាងលើ)។

ដូចពោលមកខាងលើ ប្រាសាទនេះមិនមានសិលាចារឹកបន្សល់ទុកទេ។ ប៉ុន្តែ ហេតុដែលយើងហ៊ានសន្និដ្ឋានខាងលើថា ប្រាសាទនេះមានអាយុកាលស្ថិតនៅក្នុងរចនាបថព្រៃក្មេង (គ.ស. ៦៣៥ ដល់ ៧០០) មកពីក្បាច់លម្អប្រាសាទបុសរាមជាច្រើន មានលក្ខណៈស្រដៀងខ្លាំងជាមួយក្បាច់លម្អប្រាសាទជ្រៃ (ប្រាង្គ N24)។ កាលដែលគេដឹងថាប្រាសាទជ្រៃ មានអាយុកាលស្ថិតនៅ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ក្នុងរចនាបថព្រៃក្មេង គឺគេយោងទៅលើប្រភពសិលាចារឹកដែលចារឹកនៅលើមេទ្វារប្រាសាទ (ចុះបញ្ជីលេខ K.149) ដែលរៀបរាប់អំពីអំណោយរបស់អាចារ្យម្នាក់ (គោរម្យងារ "ម្រតាញ") ទទួលបានព្រះរាជទានពីអង្គព្រះមហាក្សត្រចំនួន ៣ អង្គ គឺព្រះបាទភវវរ្ម័នទី១ ព្រះបាទមហេន្ទ្រវរ្ម័ន និងព្រះបាទឦសានវរ្ម័នទី១ ថ្វាយដល់អាទិទេពព្រះនាម "ព្រះកម្រតាងអញស្រីរត្នេស្វរ"។ ត្រង់ន័យនេះ មានន័យថា អាយុកាលនៃប្រាសាទជ្រៃ អាចស្ថិតនៅចុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ ឬអាចនៅដើមរជ្ជកាលព្រះបាទភវវរ្ម័នទី២ ដែលយើងអាចចាត់ចូលជាសិល្បៈរចនាបថព្រៃក្មេង ព្រោះវាមានលក្ខណៈខុសគ្នាច្រើនពីសិល្បៈរចនាបថសំបូរព្រៃគុក។

ជារួមមក តាមការរៀបរាប់ខាងលើនេះ ប្រាសាទបុសរាម គឺអាចចាត់ទុកថាជាសំណង់ទោលមួយដែលស្ថិតនៅដោយឡែកពីក្រុមប្រាសាទសំខាន់ៗទាំងបី នៃតំបន់ប្រាសាទសំបូរព្រៃគុក ដែលទំនងកសាងឡើងនៅស.វ.ទី៧ និងអាចចាត់ថ្នាក់ជារចនាបថព្រៃក្មេង ក្នុងចន្លោះចុងរជ្ជកាលព្រះបាទស្រីឦសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧) ឬដើមរជ្ជកាលព្រះបាទស្រីភវវរ្ម័នទី២ (គ.ស.៦៣៧-៦៥៧)។ ដោយសារកង្វះព័ត៌មានសិលាចារឹក យើងមិនដឹងថាប្រាង្គដ៏សំខាន់នេះតម្កល់អាទិទេពណាមួយឡើយ។ ប៉ុន្តែ ដោយយោងទៅលើសំណង់ជាច្រើននៅតំបន់នេះ ភាគច្រើនជាសំណង់ព្រហ្មញ្ញសាសនា ប្រាសាទនេះប្រហែលតម្កល់ព្រះសិវលិង្គ ឬអាទិទេពណាមួយនៃលទ្ធិសៃវនិយម ក្នុងនិកាយបាសុបត ឬនិកាយសៃវ។

## ឯកសារពិគ្រោះ


***ម៉ង់ រ៉ាលី*** ២០២១, *កំពង់ធំ ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ*, ភ្នំពេញ។

***ឯម ភារក្ស*** ២០១៦, ចម្លាក់កូនបង្អួច ឬគុឌុនៅសម័យមុនអង្គរ, *សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា ជំនាន់ទី២៦ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*, ភ្នំពេញ។

**Bénisti, M.** 1966, "Notes d'iconographie khmère : III. Au sujet d'un linteau de Sambor Prei Kuk", *BEFEO*, Tome 53, Paris.

**Boisselier, J.** 1966, *Asie du Sud-Est, Le Cambodge*, Tome I, Paris.

**Coedès, G.** 1943, "Quelque précisions sur la fin du Fou-Nan", *BEFEO*, Tome 43, Paris.

**Coedès, G.** 1952, *Inscription du Cambodge*, Vol IV, Hanoi.

**Parmentier, H.** 1927. *L'art Khmère primitif*, Tome I & II, Paris.


អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ១៖ ប្រាសាទបុសរាម (មើលពីមុខខាងកើត)



រូបលេខ២៖ ប្រាសាទបុសរាម (មើលពីមុខអាគ្នេយ៍)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ ប្រាសាទបុសរាម (មើលពីមុខខាងត្បូង)



រូបលេខ៤៖ ប្រាសាទបុសរាម (មើលពីមុខខាងជើង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៥៖ ប្រាសាទបុសរាម (មើលពីមុខពាយព្យ)



រូបលេខ២៦៖ ប្រាសាទបុសរាម (មើលពីមុខខាងលិច)



រូបលេខ២៧៖ ប្រាសាទបុសរាម (មើលពីមុខនិរតី)



រូបលេខ២៨៖ ប្រាសាទបុសរាម (មើលពីមុខឦសាន)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៩៖ ស្នាកស្នាមកំពែងថ្មបាយក្រៀម ប្រាសាទបុសរាម (កំពែងខាងជើង)



រូបលេខ១០៖ ទ្វារបញ្ឆោតខាងលិចប្រាសាទបុសរាម



រូបលេខ១១៖ ក្បាច់លម្អនៅតាមក្បាលជញ្ជាំងប្រាសាទបុសរាម



រូបលេខ១២៖ ក្បាច់លម្អនៅតាមក្បាលជញ្ជាំងប្រាសាទបុសរាម

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៣៖ ក្បាច់លម្អនៅតាមក្បាលជញ្ជាំងប្រាសាទបុសរាម

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION